**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ: ០១៤១/២១ ក.អ.ជ

ថ្ងៃចន្ទ ១១ រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០២១

# របាយការណ៍
# វឌ្ឍនភាពការងារប្រចាំឆ្នាំ ២០២០ និងទិសដៅការងារ ឆ្នាំ២០២១
# របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## ១.សេចក្តីផ្តើម

ក្នុងឆ្នាំ ២០២០ នេះ មានព្រឹត្តិការណ៍សំខាន់ធំៗកើតឡើងចំនួន ០២ គឺ ទី១. ការរាតត្បាតនៃមេរោគផ្លូវដង្ហើមប្រភេទថ្មី (New Corona Virus) ដែលមានឈ្មោះថាកូវីដ-១៩ ចាប់ផ្តើមក្នុងប្រទេសកម្ពុជាក្នុងអំឡុងខែកុម្ភៈ ឆ្នាំ ២០២០ ដែលមានប្រភពចេញមកពីទីក្រុងវូហាននៃប្រទេសចិន និងទី២.ជំនន់ទឹកភ្លៀងរយៈពេលខ្លី ដែលបណ្តាលមកពីព្យុះចំនួន ០៤ នៅក្នុង ខែតុលា ឆ្នាំ២០២០ កន្លងទៅនេះ ។ ករណីប្រធានស័ក្តិទាំងពីរនេះ បានធ្វើឲ្យប៉ះពាល់ដល់ជីវិតមនុស្ស និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម សំណង់ ទេសចរណ៍ និងវិស័យដទៃទៀតដែលបានរុញឲ្យអត្រាភាពក្រីក្រកើនឡើងក្នុងក្របខណ្ឌទូទាំងប្រទេស ពិសេសតំបន់ជនបទដែលមានប្រជាជនភាគច្រើនជាអ្នករស់នៅក្បែរបន្ទាត់ភាពក្រីក្រស្រាប់ ។

ក្រោមឥទ្ធិពលនៃជំងឺកូវីដ-១៩ ឆ្នាំ ២០២០ នេះ ថវិកាផ្នែកមួយផ្នែកធំត្រូវបានកាត់បន្ថយដោយការធ្វើវិចារណកម្មចំនួន ០២ ដង ដែលបណ្តាលឲ្យការអនុវត្តផែនការសកម្មភាពមួយចំនួនធំ ត្រូវបានកាត់បន្ថយដើម្បីធានាលទ្ធភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០២០ នេះ ។ ស្ថិតក្នុងបរិការណ៍នេះ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់ក្រសួងអភិវឌ្ឍន៍ជនបទបានចូលរួមចំណែកយ៉ាងសកម្មជាទីបំផុតក្នុងការដោះស្រាយបញ្ហាប្រឈមនានា ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនរួមមានការជួសជុល និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទដូចជា ផ្លូវជនបទ សំណង់សិល្បការ្យផ្សេងៗ ស្ពានអណ្តូងទឹក ស្រះទឹក សាងសង់បង្គន់អនាម័យ ដែលរងការខូចខាតដោយសារទឹកជំនន់ ផ្តល់ស្បៀង និងសម្ភារ ចាំបាច់មួយចំនួនសម្រាប់បង្ការជំងឺកូវីដ-១៩ ។ល។ ក្នុងអំឡុងពេលមានវិបត្តិនេះ ។

កិច្ចការសំខាន់មួយទៀត ក្រសួងបានផ្តើមរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ១០ឆ្នាំ ២០២១-២០៣០ ដើម្បីតម្រង់ទិសការអភិវឌ្ឍជនបទឆ្ពោះទៅចក្ខុវិស័យឆ្នាំ២០៣០ ឲ្យតំបន់ជនបទកម្ពុជាក្លាយជា ជនបទស៊ីវិល័យ តាមរយៈគោលនយោបាយចំនួន ០២ គឺ **ការលើកកម្ពស់សុខមាលភាពសង្គមជនបទកម្ពុជា** និង**ការបង្កើនសុខវឌ្ឍនភាពជនបទកម្ពុជា** ក្រោមកម្មវិធីចំនួន ០៥ អមដោយអនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពមួយចំនួនតាមតម្រូវការចាំបាច់ដើម្បីសម្រេចគោលបំណងគោលនយោបាយទាំងពីរខាងលើ ។ លទ្ធផលក្នុង ឆ្នាំ២០២០ ក្រសួងសម្រេចបានដូចខាងក្រោម៖



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

## ២.ខឌ្ឍនភាព

### ២.១. លទ្ធផលរួមរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

ក្រសួងអនុវត្តថវិកាសម្រេចបាន ៨៨,៥៧% នៃថវិការដ្ឋប្រចាំឆ្នាំ និងសម្រេចអនុវត្តផែនការសកម្មភាពទូទាំងប្រទេសសម្រេចបានប្រមាណជា ៨៦% នៃផែនការសកម្មភាពប្រចាំឆ្នាំ ២០២០ ក្នុងនោះកម្មវិធីទី១ សម្រេចបាន ៩៣% កម្មវិធីទី២ សម្រេចបាន ៨៩% កម្មវិធីទី៣, សម្រេចបាន ៧៦% និងកម្មវិធីទី៤ សម្រេចបាន ៨៥% ។

### ២.២.លទ្ធផលរបស់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ

#### ២.២.១.ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ឆ្នាំ ២០២០ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៥១៩ នាក់ (ស្រី ៤១១ នាក់) បើប្រៀបធៀបនឹងឆ្នាំ ២០១៩ មានការថយចុះចំនួន ២៨៣ នាក់ ស្រីចំនួន ៤៥ នាក់ ដោយសារមន្ត្រីរាជការនៅការិយាល័យក្រុង ស្រុក ខណ្ឌទូទាំងប្រទេសចំនួន ២៦១ នាក់ ត្រូវបានផ្ទេរសមាហរណកម្មទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមក្របខ័ណ្ឌក្រសួងមហាផ្ទៃ ការផ្ទេរក្របខ័ណ្ឌចេញទៅបម្រើការងារនៅក្រសួងស្ថាប័នផ្សេង មន្ត្រីចូលនិវត្តន៍ និងមន្ត្រីទទួលមរណៈភាព ។ ក្រសួងបានទទួលលិខិតចូលចំនួន ១ ៥១២ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ១ ៧៥៧ ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ១៩២ ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ២ ០២៣ ច្បាប់ ។

#### ២.២.២.ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងឆ្នាំ ២០២០ នេះក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ១២៧ ៩២៥,៨៣ លានរៀលស្មើនឹង ៩៥,៤២% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ២៦១ ៨៨០ លានរៀលស្មើនឹង ៩៣,៥៣% នៃច្បាប់ថវិកា។

#### ២.២.៣. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- រៀបចំវគ្គបណ្តុះបណ្តាលថវិកាកម្មវិធីដោយពិនិត្យមើលកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពដើម្បីបន្ស៊ីទៅនឹងផែនការ៥ឆ្នាំថ្មី ២០១៨-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទដោយមានអ្នកចូលរួមចំនួន ១១០ នាក់
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការរៀបចំ និងគ្រប់គ្រងផែនការថវិកានៅខេត្តកំពង់ធំដោយមានអ្នកចូលរួមចំនួន ៥៥ នាក់
- ផ្សព្វផ្សាយសវនកម្មផ្ទៃក្នុង និងប្រតិបត្តិការសវនកម្មផ្ទៃក្នុង ទៅក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួង ជួបពិភាក្សាជាមួយ **លោក អ៊ុច ចំរើន** ប្រធាន ADB ប្រចាំប្រទេសកម្ពុជាស្តីពីការអនុវត្ត សូចនាករចំនួន ៦ ធំៗ តាមប្រព័ន្ធអនឡាញរួមមាន៖ ទី១ ការបញ្ចូលភាពក្រីក្រ និងយេនឌ័រក្នុងថវិការកម្មវិធី ទី២ ការបញ្ជ្រៀតថវិកាដៃគូ DP Gender and Poverty ចូលក្នុង BSP 2021-2023 ទី៣ ការអនុវត្ត FMIS ទី៤ ការរៀបចំ FMM ទី៥ ការបោះពុម្ពផ្សាយជាសាធារណៈរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សូចនាករសមិទ្ធកម្ម និងទី៦ ការរៀបចំ Audit Performance Management ICT

- ចូលរួមប្រជុំពិនិត្យពិភាក្សាកម្រិតបច្ចេកទេសការរៀបចំថវិកាឆ្នាំ២០២១ សម្រាប់កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមប្រព័ន្ធអនឡាញ
- ចូលរៀនវគ្គបណ្តុះបណ្តាលស្តីពី "មូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការរៀបចំសូចនាករសមិទ្ធកម្មគន្លឹះ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Concepts of Economic and Finance and KPIs Preparation for Public Financial Management)" បង្ហាញដោយសាលាគោលនយោបាយសាធារណៈ លី ក្វាន់យូ នៃសាកលវិទ្យាល័យសឹង្ហបុរី រយៈពេល ០៣ ថ្ងៃ រៀបចំដោយក្រុមការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរៀនវគ្គបណ្តុះបណ្តាលស្តីពី ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) : បទពិសោធន៍ប្រទេសចិន ដែលរៀបចំឡើងដោយ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយវិទ្យាស្ថានហិរញ្ញវត្ថុ និងអភិវឌ្ឍន៍អាស៊ី បាស៊ីហ្វិក នៃទីក្រុងសៀងហៃ សាធារណៈរដ្ឋប្រជាមានិតចិន រយៈពេល ០២ ថ្ងៃ តាមប្រព័ន្ធអនឡាញ
- រៀបចំផែនការសូចនាករសមិទ្ធកម្មគន្លឹះសម្រាប់អនុវត្ត MAP 4 ដោយរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ
- រៀបចំរបាយការណ៍សមិទ្ធកម្មត្រីមាសទី១ ទី២ ទី៣ ទី៤ និងប្រចាំឆ្នាំនៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី៣ (MAP 3)
- រៀបចំសេចក្តីព្រាងផែនការសកម្មភាពដំណាក់កាលទី៤ (MAP 4)
- ចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងរបាយការណ៍វាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ ថ្នាក់ជាតិឆ្នាំ២០២០ ( Public Expenditure and Financial Accountability-PEFA )
- ចូលរួមកិច្ចប្រជុំកម្រិតគណៈកម្មាធិការគោលនយោបាយស្តីពីការអនុវត្តគោលនយោបាយវិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

### ២.២.៤. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- ចូលរួមកិច្ចប្រជុំលើកទី ១៨ នៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ។

### ២.២.៥. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- ត្រួតពិនិត្យមើលឡើងវិញផែនការថវិកាឆ្នាំ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ជួបពិភាក្សាជាមួយតំណាង ADB និង EU លើការងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី ការអនុវត្តផែនការ និងរបាយការណ៍វឌ្ឍនភាពរបស់ក្រសួង
- ពិនិត្យ កែសម្រួល និងផ្តល់យោបល់លើឯកសារផែនការសកម្មភាព ASEAN-CANADA ដោយបានបញ្ចូលបន្ថែមសកម្មភាពចំនួន ០៣ ទាក់ទងនឹងការអភិវឌ្ឍជនបទ ក្នុងផែនការសកម្មភាពទំនាក់ទំនងអាស៊ាន-កាណាដា

- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងសៀវភៅស្ថិតិស្តីពីទំនាក់ទំនង ASEAN-CHINA ឆ្នាំ២០១៨
- រៀបចំគម្រោងស្នើសុំកិច្ចសហប្រតិបត្តិការជាមួយសាធារណៈរដ្ឋឆែក តាមរយៈក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍កម្ពុជា (CDC)
- រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២១-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- រៀបចំសិក្ខាសាលាស្តីពីការស្វែងយល់ពីការអភិវឌ្ឍន៍ជនបទនៅមូលដ្ឋានលើប្រធានបទ បញ្ហាការប្រឈម និងកាលានុវត្តភាពក្នុងការងារអភិវឌ្ឍន៍ជនបទ និងទស្សនកិច្ចសិក្សាគម្រោងអភិវឌ្ឍន៍ជនបទ នៅតំបន់ទាំង៥ ដែលរួមមាន ខេត្តកំពង់ស្ពឺ ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តព្រះវិហារ
- រៀបចំកិច្ចប្រជុំពិភាក្សាការរៀបចំគោលនយោបាយជាតិឆ្នាំ ២០២១-២០៣០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន ០៧ លើក
- រៀបចំវិបស្សនាគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ ២០២១-២០៣០ លើប្រធានបទ "បញ្ហា ការប្រឈម និងកាលានុវត្តភាព" "ចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រ និង "កម្មវិធីអាទិភាព" នៅសណ្ឋាគារកំពតថ្មី ខេត្តកំពត ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ
- រៀបចំផែនការសូចនាករសមិទ្ធកម្មគន្លឹះសម្រាប់អនុវត្ត MAP 4 ដោយរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ
- រៀបចំសិក្ខាសាលាស្តីពីកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ឆ្នាំ២០២១-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រព័ន្ធអនឡាញនៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការរៀបចំផែនការថវិកាកម្មវិធី ឆ្នាំ២០២១ ស្របតាមរចនាសម្ព័ន្ធផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារហ៊ីម៉ាឡាវ៉ារី រាជធានីភ្នំពេញ
- បញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ របស់ក្រសួងដោយបានបញ្ចូលគម្រោងវិនិយោគសាធារណៈបីឆ្នាំរំកិល គម្រោងវិនិយោគថវិការដ្ឋ គម្រោងវិនិយោគហិរញ្ញប្បទានដៃគូ បញ្ហាភាពក្រីក្រ និងយេនឌ័រចូលក្នុងផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល
- រៀបចំសិក្ខាសាលាបូកសរុបលទ្ធផល នៃការរៀបចំផែនការថវិការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ ថវិកាកម្មវិធីឆ្នាំ ២០២១ និងការចុះប្រមូលទិន្នន័យតាមបណ្តារាជធានី-ខេត្ត សម្រាប់រៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ ១០ឆ្នាំ ២០២១-២០៣០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចុះប្រមូលទិន្នន័យថ្នាក់រាជធានី-ខេត្ត សម្រាប់រៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ ២០២១-២០៣០
- រៀបចំទម្រង់តារាងរបាយការណ៍សូចនាករសមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ

- ចុះតាមដានការអនុវត្តថវិកាកម្មវិធីនៅខេត្តចំនួន ១១ គឺ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង ខេត្តបន្ទាយមានជ័យ ខេត្តប៉ៃលិន ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកោះកុង និងខេត្តកំពត
- ប្រមូលផែនការសកម្មភាពរបស់មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត និងបញ្ចូលទិន្នន័យក្នុងតារាងតាមដានត្រួតពិនិត្យ
- រៀបចំរបាយការណ៍សមិទ្ធិកម្មស្តីពី លទ្ធផលក្នុងអនុវត្តថវិកាកម្មវិធីក្នុងត្រីមាសទី៣ ឆ្នាំ ២០២០ និងរៀបចំរបាយការណ៍សមិទ្ធិកម្មប្រចាំឆ្នាំក្នុងការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២០ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានផ្តល់លិខិតគាំទ្រកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការមិនមែនរដ្ឋាភិបាល ជូនអង្គការចំនួន ២៣
- បានផ្តល់លិខិតគាំទ្រកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ជូនអង្គការចំនួន ០៧
- បានផ្តល់លិខិតគាំទ្របន្តអនុស្សរណៈនៃការយោគយល់គ្នារវាងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជូនអង្គការចំនួន ០២
- បានផ្តល់លិខិតគាំទ្រសុំអន្តរាគមន៍ដើម្បីចុះបញ្ជីស្លាកលេខ ONG សម្រាប់រថយន្ត និងទោចក្រយានយន្ត របស់អង្គការមិនមែនរដ្ឋាភិបាល ជូនអង្គការចំនួន ០៤
- បានរៀបចំ បញ្ជីឈ្មោះអង្គការដែលបានបញ្ចប់កិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានចុះពិនិត្យការងារ និងសមិទ្ធផលរបស់អង្គការមិនមែនរដ្ឋាភិបាលបានចំនួន ១៤ លើក នៅខេត្តចំនួន ១៣ រួមមាន ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តមណ្ឌលគិរី ខេត្តក្រចេះ ខេត្តរតនគិរី ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តព្រះវិហារ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ ។

### ២.២.៦. ការងារអធិការកិច្ច និងសវនកម្ម

- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៩ - ២០២០ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋ នៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ចំនួន ២៥
- បានធ្វើសវនកម្មលើគម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ក្នុងការិយបរិច្ឆេទឆ្នាំ ២០១៩-២០២០ និងអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្តចំនួន ០២ រួមមាន ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ

- ចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងចំណូល-ចំណាយ និងការប្រើប្រាស់ថវិការបស់រដ្ឋ ការិយបរិច្ឆេទ ២០១៨ នៅមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីភ្នំពេញ និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្តាល
- ចុះធ្វើអធិការកិច្ច លើការងារគ្រប់គ្រងចំណូល-ចំណាយ និងការប្រើប្រាស់ថវិការបស់រដ្ឋ ការិយបរិច្ឆេទ២០១៩ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ១៩ រួមមាន៖ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ ខេត្តកំពត ខេត្តកែប ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង
- ចុះអង្កេត ស្រាវជ្រាវ និងដោះស្រាយ តាមបណ្តឹងរបស់មន្ត្រីរាជការនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង។

### ២.២.៧. ការងារអភិវឌ្ឍន៍ផ្លូវជនបទ និងមន្ទីរពិសោធន៍

- គម្រោងថែទាំខួប ឆ្នាំ ២០២០ សរុបចំនួន ៣០ គម្រោង ស្មើនឹង ៥៧ ខ្សែ ប្រវែងសរុប ៤៦៣,៤២ គ.ម លូមូល ៦០ កន្លែង និងលូប្រអប់ ០២ កន្លែង សម្រេចលទ្ធផលគិតជាមធ្យមបាន ១០០%
- គម្រោងថែទាំប្រចាំ ឆ្នាំ ២០២០ សរុបចំនួន ៣៨ គម្រោង ស្មើនឹង ២៩៨ ខ្សែ ប្រវែងសរុប ២ ៨១៣,៧៤ គ.ម លូមូល ០១ កន្លែង និងស្លាកសញ្ញាចរាចរចំនួន ២ ១៥២ ស្លាក សម្រេចលទ្ធផលគិតជាមធ្យមបាន ១០០%
- ការងារស្តាបនា កែលម្អ និងជួសជុល ឆ្នាំ ២០២០ មាន ៩៧ គម្រោង ប្រវែងសរុប ៧២៤,៩១ គ.ម សម្រេចបានលទ្ធផលជាមធ្យម ១០០ %
- គម្រោងការងារជួសជុលបន្ទាន់ កំពុងដំណើរការឯកសារចំនួន ៤៣ គម្រោង សម្រេចលទ្ធផលគិតជាមធ្យមបាន ១០០%
- ចុះត្រួតពិនិត្យ និងវាយតម្លៃគម្រោង ចំនួន ២៥៥ គម្រោង
- ចុះប្រគល់ទទួលគម្រោង ចំនួន ១០៨ គម្រោង
- ទទួលសំណាកគំរូពីស្ថាប័ននានា ចំនួន ៧២៨ សំណាក/គម្រោង
- សំណាកសម្រេចបានក្នុងការធ្វើពិសោធន៍ ចំនួន ៦៤១ សំណាក/គម្រោង
- សម្របសម្រួលរៀបចំកិច្ចប្រជុំ ចំនួន១០ លើក
- បានទទួល និងផ្តល់ការបណ្តុះបណ្តាលជំនាញពិសោធន៍នានាដល់និស្សិតបំពេញកម្មសិក្សា សរុបចំនួន ០៨ រូប (ស្រី ០១ រូប) មកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងសាកលវិទ្យាល័យបញ្ញាសាស្ត្រ ។

### ២.២.៨. ការងារផ្គត់ផ្គង់ទឹកជនបទ

- សាងសង់អណ្តូងស្នប់អាហ្វ្រីដេវ ចំនួន ២៧៥ អណ្តូង
- សាងសង់/ស្តារស្រះសហគមន៍ ចំនួន ១២ ស្រះ

- សាងសង់អាងត្រងទឹកភ្លៀងចំណុះ ៤ ម៉ែត្រគូប ចំនួន ៧០ អាង
- សាងសង់អាងត្រងទឹកភ្លៀងចំណុះ ៣៥ ម៉ែត្រគូប ចំនួន ០១ អាង
- សាងសង់ប្រព័ន្ធចែកចាយទឹកស្អាតខ្នាតសហគមន៍ ចំនួន ០៦ ស្ថានីយ៍
- សាងសង់ធុងចម្រោះទឹកស្អាត ចំនួន ១០០ ធុង
- សាងសង់ និងស្តារប្រព័ន្ធស្រោចស្រពខ្នាតតូច ចំនួន ០១ ខ្សែ
- ជួសជុលអណ្តូងស្នប់អាហ្វ្រីដេវ ចំនួន ២៧៤ អណ្តូង ។

## ២.២.៩. ការងារថែទាំសុខភាព និងអនាម័យជនបទ

- បានរៀបចំប្រជុំក្រុមការងារបច្ចេកទេស និងសិក្ខាសាលាចំនួន ១៩ លើក ដោយផ្តោតសំខាន់លើ៖ ការពង្រឹងសមត្ថភាពលើខិតបណ្ណព័ត៌មាន ការគ្រប់គ្រងប្រមូលនិងវិភាគទិន្នន័យផ្គត់ផ្គង់ទឹកស្អាត ការសំអាត និងអនាម័យជនបទ ការអភិវឌ្ឍន៍ឧបករណ៍សម្រាប់ការបណ្តុះបណ្តាល របាយការណ៍បូកសរុបទិន្នន័យតាមតំបន់ ការគ្រប់គ្រងអនាម័យតាមប្រព័ន្ធឌីជីថល និងការរៀបចំគេហទំព័រ (Website)
- ក្រុមការងារនាយកដ្ឋានបានចុះសិក្សា និងជ្រើសរើសទីតាំងដាក់បង្គន់អនាម័យជនបទ ឆ្នាំ ២០២០ នៅតាមភូមិគោលដៅចំនួន ១៥៧ ភូមិ បានសាងសង់បង្គន់ចំនួន ៣ ៤២០ ខ្នងផ្ទះ អប់រំបំផុស និងផ្សព្វផ្សាយការប្រើបង្គន់អនាម័យដល់ប្រជាពលរដ្ឋចំនួន ១៩ ៨១២ នាក់
- បណ្តុះបណ្តាល និងផ្សព្វផ្សាយគោលការណ៍ណែនាំលើកកម្ពស់អនាម័យជនបទចំនួន ៣០ លើក មានអ្នកចូលរួមចំនួន ១ ២០៣ នាក់ក្នុងខេត្តគោលដៅទាំង១៣ រួមមាន ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តត្បូងឃ្មុំ ខេត្តប៉ៃលិន ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តកោះកុង ខេត្តកែប ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និង ខេត្តស្វាយរៀង
- បានចុះអប់រំ និងផ្សព្វផ្សាយលើកកម្ពស់អនាម័យសហគមន៍ និងបានរៀបចំប្រជុំកម្មវិធីនៅថ្នាក់ខណ្ឌចំនួន ១៧ លើក ក្នុងសង្កាត់ទួលសង្កែ និងសង្កាត់ស្វាយប៉ាក ដោយផ្តោតសំខាន់លើ៖ ប្រជុំប្រចាំត្រីមាស ពិនិត្យ តាមដាន និងវាយតម្លៃពីវឌ្ឍនភាពការងារលើកកម្ពស់អនាម័យ ការចែកកន្ត្រកអនាម័យកុមារ និងសាប៊ូ និង ការអប់រំ និងផ្សព្វផ្សាយពីវិធានការការពារជម្ងឺកូវីដ-១៩ មានអ្នកចូលរួមសរុប ៤៥០ នាក់
- បានចូលរួមប្រជុំ ចុះតាមដាន និងបើកវគ្គបណ្តុះបណ្តាលសហគមន៍ដឹកនាំអនាម័យចំនួន ២៣ លើកដោយផ្តោតសំខាន់លើ៖ ប្រជុំប្រចាំឆមាស ការអនុវត្តកម្មវិធី CLTS ផ្ទៀងផ្ទាត់ភូមិODF ការកត់ត្រាសៀវភៅទិន្នន័យនិងផែនទីភូមិ ការទុកដាក់សម្រាម លាមកសត្វ និងសម្អាតបរិស្ថានជុំវិញផ្ទះ និងផ្សព្វផ្សាយការទប់ស្កាត់ជម្ងឺកូវីដ-១៩
- បានផ្តល់ចានបង្គន់ដល់ប្រជាពលរដ្ឋជាលក្ខណៈឯកជនចំនួន ២៣៥ បង្គន់ និងបានអប់រំអនាម័យដល់ប្រជាពលរដ្ឋចំនួន ២ ០៥៨ នាក់ ។

## ២.២.១០. ការងារអភិវឌ្ឍន៍សហគមន៍

- បានធ្វើការបណ្តុះបណ្តាល គ.អ.ភ ស្តីពីតួនាទី និងភារកិច្ច គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ការធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ និងសញ្ញាណចលនាភូមិថ្មី បានចំនួន ៥៦ វគ្គ មកពី ៣៩២ ភូមិ ដែលមានសិក្ខាកាមសរុប ១ ៩៦០ នាក់ ស្រី ៤៨៥ នាក់
- ធ្វើបច្ចុប្បន្នភាព គ.អ.ភ បានចំនួន ២ ១៧៨ ភូមិ ក្នុងនោះ ភូមិមានសកម្មភាពចំនួន ១ ៩៥២ ភូមិ ភូមិគ្មានសកម្មភាពចំនួន ១២៣ ភូមិ ភូមិមានអង្គការគាំទ្រចំនួន ០៧ ភូមិ ផ្លាស់ប្តូរសមាជិកភាពថ្មីចំនួន ២ ៣០១ នាក់ នៃភូមិបច្ចុប្បន្នភាព
- បានគាំទ្រសកម្មភាពអភិឌ្ឍន៍ភូមិចម្រុះរួមមាន កូនឈើហូបផ្លែ ពូជសត្វ និងស្រះគ្រួសារ លើភូមិគោលដៅចំនួន ០៥ ភូមិ នៃខេត្តចំនួន ០៤ ខេត្តគឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ឆ្នាំង ខេត្តស្វាយរៀង និងខេត្តព្រៃវែង
- បណ្តុះបណ្តាលដល់គ្រួសារសហគមន៍ស្តីពី សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្តិ៍ចំនួន ០៧ វគ្គ សិក្ខាកាម ចូលរួមសរុបចំនួន ២៤៥ នាក់ ស្រី ១៧៤
- ការិយាល័យអប់រំក្រៅប្រព័ន្ធ នៅក្នុងឆ្នាំ ២០២០ បានបើកវគ្គបណ្តុះបណ្តាលចំនួន ០៧ វគ្គ មានសិក្ខាកាមចូលរួមចំនួន ២៤៥ នាក់ ស្ត្រី ១០៥ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងវែងចំនួន ១៥ វគ្គ មានសិក្ខាកាមចំនួន ៤៣៤ នាក់ ស្រី ២១០ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានបើកវគ្គបណ្តុះបណ្តាលនៅក្រោមជ្ឈមណ្ឌលបានចំនួន ១០ វគ្គ (រយៈពេល ១០ ថ្ងៃ) សិក្ខាកាមសរុបចំនួន ២០០ នាក់ ស្រី ចំនួន ៧៤ នាក់ ។

## ២.២.១១. ការងារបណ្តុះបណ្តាល

- ការបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា និងការសិក្សារយៈពេលវែងក្នុងប្រទេសសម្រាប់ ឆ្នាំ ២០២០ មានចំនួន ៤៥១ លើក ដែលមានសិក្ខាកាមចូលរួមសរុប ២ ៨២២ នាក់ (ស្រីចំនួន ៥០៤ នាក់)
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៩៥៤ នាក់ ស្រី ១៨០ នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ០៧ នាក់ ស្រី ០១ នាក់
- បានសហការជាមួយស្ថាប័ន និងអង្គភាពជាដៃគូសម្រាប់ការងារបណ្តុះបណ្តាលបានចំនួន ២៩ លើក
- បានរៀបចំបើកវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាក្រោមថវិកាកម្មវិធី និងក្រោមថវិកាកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលចំនួន ១០ លើក ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៦១៩ នាក់ (ស្រីចំនួន ៨២នាក់)
- លទ្ធផលក្រោយពីបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈកម្រិតមូលដ្ឋាន រយៈពេលវែង (៤ ខែ) ទៅមានសិក្ខាកាមសរុបចំនួន ៤៤ នាក់ (ស្រី ៣១ នាក់) នៅក្នុងចំណោមសិក្ខាកាមសរុបចំនួន ៤៤៤ នាក់ ដែលបានយកចំណេះដឹង និងជំនាញទៅប្រកបមុខរបរ និងបម្រើការងារ ដើម្បីចិញ្ចឹមខ្លួន និងក្រុមគ្រួសារឱ្យមានការរីកចម្រើនថែមមួយកម្រិតទៀត ដែលតួលេខនេះគិតតែទៅលើវគ្គជំនាញតែប៉ុណ្ណោះ

- លទ្ធផលសរុបសម្រាប់ការបណ្តុះបណ្តាលជំនាញនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង ១៣ ក្នុងឆ្នាំ២០២០ ជូនប្រជាជននៅជនបទសរុបបានចំនួន ២ ៣៩៨ នាក់ (ស្រី ១ ១៧៤ នាក់)។

### ២.២.១២. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពុងអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយ សហគមន៍សន្សំប្រាក់បានផ្តល់ឥណទានសរុបចំនួន ៤ ២០៤ ៦០៨ ២៣៥ រៀល (បួនបីលានពីររយបួនលានប្រាំមួយរយប្រាំបីពាន់ពីររយសាមសិបប្រាំរៀល) ស្មើនឹង ១ ០៧០ ៣៧៨,០២ ដុល្លារអាមេរិក (មួយលានចិតសិបពាន់បីរយចិតសិបប្រាំបីដុល្លារនិងពីរសេន) (១USD=៤000រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ២៣៧ នាក់ នៅភូមិគោលដៅចំនួន ១៩១ ភូមិ ៧៤ ឃុំ ៣៣ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥
- បានចុះត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងឥណទានចំនួន ១២ លើកនៅខេត្តកំពង់ចាម ខេត្តកំពត ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តត្បូងឃ្មុំ
- បានចុះពិនិត្យ និងវាយតម្លៃសកម្មភាពក្រោយពីវគ្គបណ្តុះបណ្តាល ចំនួន ០៤ លើក ០៤ ខេត្ត នៅ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តតាកែវ
- បានរៀបចំវគ្គបណ្តុះបណ្តាល និងការធ្វើសិប្បកម្មផលិតសាប៊ូ ចំនួន ១០ វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន ២០១ នាក់ នៅខេត្តកំពង់ឆ្នាំង ខេត្តបាត់ដំបង និងខេត្តសៀមរាប
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីគំនិតផ្តួចផ្តើម និងការគ្រប់គ្រងអាជីវកម្មខ្នាតតូចចំនួន ០៣ លើក ដែលមានសិក្ខាកាមចូលរួមចំនួន ១២២ នាក់ នៅខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តកំពង់ចាម
- បានរៀបចំវគ្គបណ្តុះបណ្តាលបង្កើតការកែច្នៃផលិតផលសហគមន៍ជនបទ ចំនួន ០១ លើក ដែលមានសិក្ខាកាមចូលរួមចំនួន ២៧ នាក់ នៅខេត្តកំពង់ឆ្នាំង ។

### ២.២.១៣. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- រៀបចំលិខិតទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិចកួយ ចំនួន ០១ ភូមិ នៅខេត្តក្រចេះ
- ប្រជុំពេញអង្គ របស់ជនជាតិដើមភាគតិច ដើម្បីពិនិត្យ និងអនុម័តលើខ្លឹមសារព្រាង
- បទបញ្ជាផ្ទៃក្នុងសហគមន៍ជនជាតិដើមភាគតិចចារាយ ព្រៅ ទំពួន និងគ្រឹង ចំនួន ០៤ ភូមិនៅខេត្តរតនគិរី
- ចូលរួមកិច្ចប្រជុំពេញអង្គ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ និងគណៈកម្មាធិការជនជាតិដើមភាគតិច ចំនួន ០៩ ភូមិ នៅខេត្តរតនគិរី។

### ២.២.១៤.ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤

ក្នុងឆ្នាំ ២០២០ នេះ លេខាធិការដ្ឋានក្រុមការងារចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានចំនួន ៩២ ករណី ក្នុងនោះតាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រសួងដោះស្រាយបានចំនួន ២៣ ករណី ។

### ២.២.១៥. ការងារយេនឌ័រ

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសមត្ថភាពយេនឌ័រ និងផែនការយុទ្ធសាស្រ្តនារីរតនៈទី៥ ឆ្នាំ ២០១៩-២០២៣
- ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីផលប៉ះពាល់នៃកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ ។

### ២.២.១៦. ការងារប្រយុទ្ធនឹងជំងឺអេដស៍

- ប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០២១ ។

## ២.៣. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការទ្វេភាគី និងពហុភាគី

### ២.៣.១. គម្រោងកែលម្អផ្លូវជនបទ ជំហាន ២

គិតត្រឹមដំណាច់ឆ្នាំ ២០២០ នេះ គម្រោងសម្រេច៖

- បានបញ្ចប់ការសាងសង់ផ្លូវ នៅខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ដែលមានប្រវែងសរុប ៥៦១,៣០ គ.ម
- បានបញ្ចប់ការសាងសង់ប្រឡាយទឹកស្រោចស្រពដំណាំ និងមណ្ឌលសុខភាព នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១០៤,០៨ គ.ម សម្រេចបាន ៨៩,៨៥%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៧៨,៩៦%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១២៦,៣០ គ.ម សម្រេចបាន ៨៥,១៦%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៩១,៨៩%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ ខ្សែ ប្រវែង ១១៣,៤០ គ.ម សម្រេចបាន ៩២,៦៨% ។

### ២.៣.២. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ

គម្រោងបានទទួលការអនុម័តចំនួន ២ ៦៧៣ គម្រោង ប្រវែង ២ ៤០៧ ៨៥៨ ម៉ែត្រ បាន និងកំពុងអនុវត្តចំនួន ១ ៥៨០ គម្រោង ប្រវែង ១ ៤៣៧ ៥០៤ ម៉ែត្រ ក្នុងខេត្តគោលដៅចំនួន ១៧ ក្នុងនោះបានបញ្ចប់ការងារ ចំនួន ១ ០៣១ គម្រោង ប្រវែង ៩១៤ ២១៧ ម៉ែត្រ ។

### ២.៣.៣.គម្រោងការអភិវឌ្ឍសមាហរណកម្មតាមដងទន្លេមេគង្គដំហាន២

គម្រោងការអភិវឌ្ឍន៍សមាហរណកម្មតាមដងទន្លេមេគង្គដំហាន២ ដែលជាហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគីជាមួយសាធារណៈរដ្ឋប្រជាមានិតចិនដំហានទី២ដែលមានលទ្ធផលដូចខាងក្រោម៖

- សាងសង់បង្គន់អនាម័យ ចំនួន ៣៦ បង្គន់
- សាងសង់ចង្ក្រានដុតអុសបច្ចេកទេស ចំនួន ៣៥ កន្លែង
- ដាក់ផ្លាកអប់រំផ្សព្វផ្សាយពីអនាម័យ និងបរិស្ថាន ចំនួន ៨០ ផ្លាក
- ចុះត្រួតពិនិត្យសមិទ្ធផលគម្រោងនៅខេត្តគោលដៅរួមមានខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តកណ្តាល និងខេត្តព្រៃវែង។

### ២.៣.៤. គម្រោងមូលនិធិសហប្រតិបត្តិការមេគង្គគង្គា-ឥណ្ឌា

គម្រោងសហប្រតិបត្តិការមេគង្គ-គង្គាជាគម្រោងមូលនិធិសហប្រតិបត្តិការជាមួយសាធារណៈរដ្ឋឥណ្ឌាក្នុងក្របខណ្ឌមេគង្គ-គង្គា ។ ឆ្នាំ ២០២០ គម្រោងសម្រេចបានដូចខាងក្រោម៖

- សាងសង់បង្គន់អនាម័យ ចំនួន ២០ បង្គន់
- ដាក់ផ្លាកអប់រំផ្សព្វផ្សាយពីអនាម័យ និងបរិស្ថាន ចំនួន ២២ ផ្លាក
- សាងសង់កសិដ្ឋានចិញ្ចឹមមាន់ ចំនួន ០៤ កន្លែង
- កំពុងរៀបចំសៀវភៅអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងបញ្ឈប់ការផឹកទឹកដែលមានជាតិអាសេនិច
- បានចុះត្រួតពិនិត្យសមិទ្ធផលគម្រោង ចំនួន ០១ លើក ។

### ២.៣.៥. គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍

គិតត្រឹមដំណាច់ឆ្នាំ ២០២០ នេះ គម្រោងសម្រេច៖

- បាន និងកំពុងសាងសង់ផ្លូវ ចំនួន ០៧ ខ្សែ ប្រវែង ៤៩,៨៩គីឡូម៉ែត្រ នៅខេត្តកណ្តាល ដោយសម្រេចបាន ១៦,១៣%
- បានចុះផ្សព្វផ្សាយលើការងារសេង្គម និងបរិស្ថាននៅតាមខ្សែផ្លូវដែលត្រូវសាងសង់ នៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង
- បានទទួលការឯកភាពពីធនាគារពិភពលោក លើរបាយការណ៍វាយតម្លៃឯកសារដេញថ្លៃសាងសង់ផ្លូវកញ្ចប់ទី ៣ ស្ថិតនៅក្នុងខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប
- បានចេញលិខិតជូនដំណឹងស្តីពីលទ្ធផលនៃការដេញថ្លៃដល់ក្រុមហ៊ុនទាំង ១៣ ដែលបានចូលរួមការដេញថ្លៃកញ្ចប់ទី ៣
- កំពុងធ្វើការវាយតម្លៃឯកសារដេញថ្លៃជ្រើសរើសក្រុមហ៊ុនសម្រាប់ការងារ Institutional Strengthening and Capacity Building for Disaster Resiliency of Rural Roads ។

### ២.៣.៦. គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ជំហាន ២

គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទ ជំហាន២ អនុវត្តរយៈពេល ១២ខែ ក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលក្នុងនោះគម្រោងផ្គត់ផ្គង់

ទឹកជនបទអនុវត្តនៅខេត្តគោលដៅចំនួន ១០ គឺខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តកំពត ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ចាម និងគម្រោងកែលម្អផ្លូវជនបទ ជំហាន ២ អនុវត្តនៅខេត្តគោលដៅចំនួន ០៦ រួមមាន ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកណ្ដាល ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ ។ នៅក្នុងឆ្នាំ ២០២០ នេះ គម្រោងសម្រេច៖

- ជីកអណ្ដូងបានចំនួន ៩៨ អណ្ដូង
- តម្លើងស្នប់ ចំនួន ៨១១ ស្នប់
- បានជីកស្រះ ចំនួន ៣៦ ស្រះ
- បាន និងកំពុងសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ១១៩,៥៥ គ.ម នៅខេត្តគោលដៅទាំង ០៦ សម្រេចបាន ៣៥,២៤ % ។

### ២.៣.៧. គម្រោងពិពិធកម្មកសិកម្មកម្ពុជា

គម្រោងពិពិធកម្មកសិកម្មកម្ពុជាអនុវត្តរយៈពេល ០៦ឆ្នាំ គិតចាប់ពី ឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៤ ។ គម្រោងមានគោលបំណង ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍខ្សែច្រវ៉ាក់ផលិតផល កសិកម្មចម្រុះ នៅក្នុងតំបន់ភូមិសាស្ត្រ នៅខេត្តគោលដៅចំនួន ១៣ រួមមាន ខេត្តត្បូងឃ្មុំ ខេត្តកណ្ដាល ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តក្រចេះ ខេត្តកំពង់ឆ្នាំង និងរាជធានីភ្នំពេញ ។ នៅក្នុងឆ្នាំ ២០២០ នេះគម្រោងសម្រេច៖

- បើកឯកសារដេញថ្លៃចំនួន ០២ គឺ ការផ្គត់ផ្គង់គ្រឿងសង្ហារឹម និងការផ្គត់ផ្គង់ម៉ូតូចំនួន ១៣ គ្រឿង
- រៀបចំផែនការថវិកាសម្រាប់ឆ្នាំ ២០២១
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយគម្រោងពិពិធកម្មកសិកម្មកម្ពុជា នៅថ្នាក់ខេត្តទាំង១២
- មន្ត្រីថ្នាក់ខេត្តបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយគម្រោងពិពិធកម្មកសិកម្មកម្ពុជាថ្នាក់ស្រុក ក្នុងខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តកណ្ដាល ។

### ២.៣.៨. គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា

គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា (CSLEP) ជាគម្រោងក្រោមហិរញ្ញប្បទានឥណទានសហប្រតិបត្តិការ ពីធនាគារពិភពលោក និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ០៥ ឆ្នាំ (២០២០-២០២៥) ។ គម្រោងមានគោលបំណងស្ដាបនាផ្លូវក្រាលកៅស៊ូពីរជាន់ ប្រភេទ DBST និងប្រភេទផ្លូវបេតុង នៅខេត្តគោលដៅចំនួន ០៧ រួមមាន ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកោះកុង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ ។ ក្នុងឆ្នាំ ២០២០ នេះគម្រោងសម្រេចបាន ៖

- រៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយអង្គភាពអនុវត្តគម្រោង ដើម្បីណែនាំអំពីព័ត៌មានទូទៅ របស់គម្រោង និងការកំណត់ខ្សែផ្លូវ

- បានប្រមូលទិន្នន័យបច្ចុប្បន្នភាពខ្សែផ្លូវ ដោយផ្អែកលើទីតាំងតំបន់អេកូទេសចរណ៍ទាំង ១៥ នៅ តាមបណ្តាខេត្តគោលដៅទាំង ០៧
- ចុះប្រមូលទិន្នន័យ និងពិនិត្យប្រព័ន្ធចែកចាយទឹកស្អាត ស្ថានភាពអនាម័យ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម នៅខេត្ត កំពង់ស្ពឺ ខេត្តពោធិ៍សាត់ និងខេត្តសៀមរាប
- ចូលរួមចុះសិក្សាវាយតម្លៃបឋមលើផលប៉ះពាល់សង្គមផ្អែកជនជាតិដើមភាគតិច នៅខេត្តបាត់ដំបង ខេត្តកំពង់ស្ពឺ ខេត្តពោធិ៍សាត់ និងខេត្តកោះកុង
- បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងប្លង់គណនី គម្រោង នៅសណ្ឋាគារភ្នំពេញ
- បានបង្កើតសៀវភៅណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការផ្គត់ផ្គង់សម្ភារ (ប្លង់គណនីទម្រង់ /គម្រូគណនេយ្យ និងគម្រូរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ/ប្រចាំឆមាស/ប្រចាំឆ្នាំ)។

### ២.៣.៩. លទ្ធផលនៃកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល (NGOs)

ក្រៅពីគម្រោងដែលមានកិច្ចសហប្រតិបត្តិការគាំទ្រជាមួយដៃគូអភិវឌ្ឍន៍ និងបណ្តាប្រទេសជាមិត្ត ក្រសួងក៏បានសហការជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិផងដែរ សរុបមានចំនួន ៤៧ អង្គការ ដែលបានផ្តល់កិច្ចសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទរួមមាន៖ (១).អង្គការទស្សនៈពិភពលោក (World Vision), (២).អង្គការមូលនិធិនៃក្តីសង្ឃឹម (OHF), (៣).អង្គការ Saemaul Globalization Foundation, (៤).អង្គការសមាគមសម្របសម្រួល និងអភិវឌ្ឍន៍សង្គម (RDSA), (៥).អង្គការ Life Water, (៦).អង្គការ FH Cambodia, (៧).អង្គការជៀកូណៀខាមបូឌា, (៨).អង្គការរើលកាណាន់, (៩).អង្គការ Engineers Without Borders (EWB), (១០).អង្គការអាគ្រីស៊ុតអន្តរជាតិកម្ពុជា, (១១).អង្គការឆាលហ្វានកម្ពុជា (Child Fund Cambodia), (១២).អង្គការគណៈកម្មាធិការ មិត្តភាពម៉ិនណូណៃថ៍ (MCC), (១៣).អង្គការអង្គការអ្នកជិតខាងកម្ពុជា (NOC), (១៤).អង្គការសហគ្រាសអភិវឌ្ឍន៍អន្តរជាតិកម្ពុជា (iDE), (១៥).អង្គការស៊ីជាប់បែលយូអេស (CWS), (១៦).អង្គការសហការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា (PADEK), (១៧).អង្គការមូលនិធិអ៊ីសមីតវេសត៍ (EMW), (១៨).អង្គការសេចក្តីសង្ឃឹមពិភពលោកអន្តរជាតិ, (១៩). អង្គការស្អាតកម្ពុជា, (២០).អង្គការកម្មវិធីអភិវឌ្ឍន៍អាស៊ីអាគ្នេយ៍ (SADP), (២១).អង្គការអភិវឌ្ឍន៍និងសង្គ្រោះសកលកម្ពុជា (CGA), (២២).អង្គការសម្ព័ន្ធបេសកកម្ម (Mission Alliance), (២៣).អង្គការការីតាសអូស្ត្រាលី (ACR), (២៤).អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូរក្នុងសកម្មភាព (DPA), (២៥).អង្គការចេរភាពកម្ពុជា, (២៦).អង្គការស៊ីប៊ីអិនកម្ពុជា (CBN), (២៧).អង្គការ Samaritan's Purse International Relief, (២៨).អង្គការ World Renew, (២៩).អង្គការអង្គការហ្វូដណេប៊ីកម្ពុជា, (៣០).អង្គការជីវិតថ្លៃថ្នូរ, (៣១).អង្គការទឹកស្អាត១០០១, (៣២).អង្គការ CAFOD, (៣៣).អង្គការអភិវឌ្ឍន៍សហគ្រាសទឹក និងអនាម័យកម្ពុជា (Water SHED Cambodia), (៣៤).អង្គការភ្លែនអន្តរជាតិកម្ពុជា, (៣៥).អង្គការអេស៊ានអោថវិច្ឆបម្រើកម្ពុជា (AOC), (៣៦).អង្គការអភិវឌ្ឍន៍ធនធានអន្តរជាតិ (RDI), (៣៧).អង្គការអាក់សិនអេតកម្ពុជា (AAC), (៣៨).អង្គការ Muslim Aid Cambodia (MAC), (៣៩).អង្គការ WaterAid, (៤០).អង្គការហេហ្វីកម្ពុជា, (៤១).អង្គការ

Johanniter International Assistance ( JIA ), ( ៤២ ). អង្គការសួនមូលនិធិ ( TGF ), ( ៤៣ ). អង្គការអុកស្វាមនៅកម្ពុជា ( Oxfam Cambodia ), ( ៤៤ ).អង្គការ People In Needs ( PIN ), ( ៤៥ ).អង្គការការីតាសកម្ពុជា, ( ៤៦ ).សមាគមន៍កូប្រ៉ាស៊ីមូស្លីមកម្ពុជា, និង( ៤៧ ).សាកលវិទ្យាល័យអន្តរជាតិ (IU)។

អង្គការក្រៅរដ្ឋាភិបាលទាំងនេះ មានបេសកកម្មផ្តោតជាសំខាន់លើះ( ១ ).បង្កើនសមត្ថភាពសិស្ស និងនិស្សិតក្នុងសហគមន៍ និងសាងសង់អណ្តូងទឹក និងប្រឡាយទឹក, ( ២ ).កសាងសមត្ថភាពបុគ្គលិកអង្គការដៃគូឲ្យក្លាយជាអ្នកបណ្តុះបណ្តាលការងារអភិវឌ្ឍន៍ និងជាអ្នកអនុវត្តជាក់ស្តែងកសាងសមត្ថភាពគណៈកម្មការអភិវឌ្ឍន៍ភូមិ និងកម្មវិធីសន្តិសុខស្បៀង, ( ៣ ).អប់រំសហគមន៍ឲ្យមានសុខភាពល្អ វិទ្យាស្ថានអភិវឌ្ឍន៍កសិកម្ម និងសហគមន៍ប្រកបដោយនិរន្តរភាព មជ្ឈមណ្ឌលបច្ចេកវិទ្យាសមស្របកម្ពុជា និងមជ្ឈមណ្ឌលកសិកម្មនិរន្តភាពក្នុងតំបន់, ( ៤ ).អប់រំសហគមន៍ឲ្យមាន សុខភាពល្អ វិទ្យាស្ថានអភិវឌ្ឍន៍កសិកម្ម និងសហគមន៍ប្រកបដោយនិរន្តរភាព មជ្ឈមណ្ឌលបច្ចេកវិទ្យាសមស្របកម្ពុជា, ( ៥ ).បណ្តុះបណ្តាលជំនាញមូលដ្ឋាន អភិវឌ្ឍន៍សហគមន៍ និងជួយកុមារកំព្រា, ( ៦ ).ដំឡើងម៉ាស៊ីនផលិតទឹក បណ្តុះបណ្តាលបច្ចេកទេសផលិតទឹក អភិវឌ្ឍន៍សហគ្រាសទឹក និងអនាម័យ, ( ៧ ).អភិវឌ្ឍន៍ទីផ្សារដើម្បីទ្រទ្រង់អ្នកក្រីក្រ, ( ៨ ).បំណិនជីវិតនៃក្តីសង្ឃឹម លើកម្មវិធីអប់រំ កសិកម្ម សុខភាពការសន្សំប្រាក់ និងបង្កើនប្រាក់ចំណូលគ្រួសារ, ( ៩ ).ទឹកស្អាត និងសន្តិសុខស្បៀងជាលក្ខណៈគ្រួសារ, ( ១០ ).ផ្គត់ផ្គង់ទឹកស្អាតនៅជនបទ អនាម័យសហគមន៍ និងកម្មវិធីអនាម័យ, ( ១១ ).អភិវឌ្ឍន៍សហគមន៍ចម្រុះ, ( ១២ ).លើកកម្ពស់គុណភាពទឹកស្អាត ផ្តល់ធុងចម្រោះទឹកស្អាត ផ្តល់ប្រព័ន្ធចម្រោះទឹកតាមផ្ទះ វិភាគសារជាតុអាសេនិក និងលុបបំបាត់ការបរិភោគ ទឹកអាសេនិក សាងសង់អាងស្តុកទឹកភ្លៀង និងការផ្សព្វផ្សាយបញ្ហាសុខភាព និងអនាម័យក្នុងភូមិជាមួយស្ត្រីនិងកុមារ, ( ១៣ ).កម្មវិធីសន្តិសុខស្បៀង, ( ១៤ ).អប់រំស្តីពីការទប់ស្កាត់សម្រាប់សហគមន៍ យុវជនមិនប្រើប្រាស់គ្រឿងញៀន WATSAN និងការថែទាំសុខភាពបឋម បង្កើតប្រាក់ចំណូល និងមីក្រូហិរញ្ញវត្ថុ បណ្តុះបណ្តាលជំនាញសម្រាប់អភិវឌ្ឍន៍ជីវភាព, ( ១៥ ).និរន្តភាពអនាម័យដើម្បីទាំងអស់គ្នា (SSH4A) ការផ្តល់សេវាកម្មវិមជ្ឈការអនាម័យជនបទ និងNOURISH កម្មវិធីសមាហរណកម្មវិធីអាហារូបត្ថម្ភ ទឹក អនាម័យ និងកសិកម្ម, ( ១៦ ).លើកកម្ពស់ជីវភាពប្រជាជនកម្ពុជានៅជនបទ តាមរយៈអភិវឌ្ឍន៍សហគមន៍ចម្រុះទឹកស្អាត និងអនាម័យ កម្មវិធីភាពជាដៃគូជាមួយអង្គការក្នុងស្រុក និងបម្រែបម្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យនៃគ្រោះធម្មជាតិ, ( ១៧ ).លើកកម្ពស់ជីវភាពធន់ទ្រាំរបស់សហគមន៍តាមរយៈសហគមន៍សន្សំប្រាក់ ការបង្កើនផលិតកម្មកសិកម្ម និងមុខរបរ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការបម្រែបម្រួលអាកាសធាតុ, ( ១៨ ). អាហារូបត្ថម្ភ ការបង្ហាពីជម្ងឺឆ្លងផ្សេងៗ អក្ខរកម្ម បំណិនជីវិត ការការពារកុមារ និងការអប់រំបំប៉ន់ផ្នែកវិញ្ញាណ, ( ១៩ ).ទឹកស្អាត និងអនាម័យឆ្ពោះទៅរកនិរន្តរភាពសម្រាប់មនុស្សគ្រប់រូប, ( ២០ ).អភិវឌ្ឍន៍សហគមន៍ អប់រំបំប៉ន និងភាពជាដៃគូ, ( ២១ ).សមាហរណកម្មអាហារូបត្ថម្ភ និងអនាម័យ "NOURISH", ( ២២ ).លើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន និងលើកម្ពស់សុខុមាលភាពរបស់ប្រជាជន, ( ២៣ ).លើកស្ទួយសុខមាលភាពសហគមន៍, ( ២៤ ).ខួងអណ្តូងស្នប់, ( ២៥ ).លើកកម្ពស់អាហារូបត្ថម្ភ និងសុខុមាលភាពរបស់ប្រជាជននៅជនបទ, ( ២៦ ).អប់រំសហគមន៍ឲ្យមានសុខភាពល្អ ផ្នែកអនាម័យ កសិកម្ម ការចិញ្ចឹមសត្វ, ( ២៧ ).

កម្មវិធីប្រពលវប្បកម្ម និងពិពិធកម្មកសិកម្មតាមបែបក្សេត្របរិស្ថាន, (២៨).អភិវឌ្ឍន៍ជនបទចម្រុះ, (២៩).ចលនាភូមិថ្មី ដែលបានបំពេញ ការងារនៅរាជធានី-ខេត្តគោលដៅទាំង ២៥ នៅទូទាំងប្រទេស ។ លទ្ធផលក្នុងឆ្នាំ ២០២០ នេះរួមមាន៖ សាងសង់សាលារៀនបាន ១៣ ខ្នង, សាងសង់ព្រះវិហារ ០៦ ខ្នង, សាងសង់ផ្ទះ ៤១ ខ្នង, ជួសជុលផ្ទះ ០១ ខ្នង, ចែកទឹកត្រី ១៦ ៩២ ដប, ផ្តល់ពូជសណ្តែកសៀង ២ ១៤៧ គីឡូក្រាម, ចែកពូជស្រូវ ២៥ ២៤៥ គីឡូក្រាម, ចែកអង្ករ ២៤,៤៥ តោន, ចែកកូនឈើ ៣ ៩៩៧ ដើម ។ ផ្តល់សៀវភៅដល់សិស្សានុសិស្ស ចំនួន ២ ៣៥០ ក្បាល ។ បង្កើតសួនបន្លែតាមផ្ទះបាន ២៧១ កន្លែង, តម្លើងផ្ទាំងប៉ាណូផ្សព្វផ្សាយអនាម័យ ៧៦ ផ្ទាំង ។ ចែកម៉ាស៊ីនបូមទឹក ១០២ គ្រឿង និងចែកផ្ទាំងសូឡា ១១៦ ផ្ទាំង ។ ផ្តល់ពូជមាន់ ៩ ៨៦៥ ក្បាល, ពូជទា ៩៤០ ក្បាល, ពូជគោ ១៣៤ ក្បាល និងពូជជ្រូក ៩០ ក្បាល ។ ផ្តល់កង់ ១០០ គ្រឿងដល់សិស្ស, ផ្តល់គោយន្ត ១៨ គ្រឿង និងទូកម៉ាស៊ីន ៣៩ គ្រឿង ។ សាងសង់រោងដាក់ម៉ាស៊ីនច្រូតស្រូវ ០១ កន្លែង ។ សាងសង់រោងម៉ាស៊ីនកែច្នៃសាច់ ០១ ខ្នង និងផ្តល់ម៉ាស៊ីនបោកស្រូវ ០៣ គ្រឿង ។

## ៣. ទិសដៅបន្ត

### ៣.១. បញ្ហាប្រឈម

- កិច្ចសន្យាមួយចំនួនមានភាពយឺតយ៉ាវបណ្តាលឱ្យស្ទះដល់ដំណើរការរៀបចំរបាយការណ៍គម្រោងសាងសង់
- កង្វះឧបករណ៍មួយចំនួនលើការងារធ្វើពិសោធន៍ផ្នែកដី ផ្នែកបេតុង ផ្នែកកៅស៊ូ និងការងារគ្រប់គ្រងឧបករណ៍ពិសោធន៍
- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- សមត្ថភាពចូលរួមផ្តល់សេវារបស់វិស័យឯកជននៅមានកម្រិត
- ទម្លាប់សង្គមក្នុងការបន្ទោបង់ពាសវាលពាសកាល មិនទម្លាប់ផឹកទឹកស្អាត និងការលាងដៃឲ្យបានត្រឹមត្រូវ ខ្វះការយល់ដឹង ដែលនាំឲ្យកម្រិតវិនិយោគពីគ្រួសារទាប
- ទីផ្សារអនាម័យនៅមានកម្រិត (បច្ចេកវិទ្យា ផលិតផល ការផ្គត់ផ្គង់បរិក្ខារអនាម័យ)
- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- គ.អ.ភ ពុំមានស្នាក់ការសម្រាប់ធ្វើការងារ
- ស្ថាប័ន ឬអង្គការមួយចំនួន មិនបានប្រើប្រាស់ គ.អ.ភ ហើយបានបង្កើតជនបង្គោលផ្សេងៗពី គ.អ.ភ
- កិច្ចសហការជាមួយអង្គការ ដៃគូអភិវឌ្ឍន៍ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត នៅមានកម្រិតនៅឡើយលើវិស័យឥណទានជនបទ និងសកម្មភាពបង្កើនប្រាក់ចំណូលផ្សេងៗ ។

### ៣.២. ទិសដៅតាមអង្គភាព

- បន្តបញ្ចប់ការរៀបចំខ្លឹមសារគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ២០២១-២០៣០ របស់ក្រសួងលើជំពូកទី៤ និងទី៥ ដែលជាជំពូកចុងក្រោយ
- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ១០ ឆ្នាំ២០២១-២០៣០
- រៀបចំផែនការវិនិយោគសាធារណៈ៣ឆ្នាំរំកិល PIP ២០២២-២០២៤

- រៀបចំផែនការយុទ្ធសាស្ត្រថវិកា BSP ២០២២-២០២៤
- រៀបចំផែនការថវិកាតាមកម្មវិធីទាំង ៥ របស់ក្រសួង PB-២០២១
- រៀបចំផែនការគ្រប់គ្រងស្ថិតិអភិវឌ្ឍន៍តំបន់ទាំង ៥ នៃតំបន់ជនបទកម្ពុជា
- រៀបចំសិក្ខាសាលាបូកសរុប និងវាយតម្លៃលទ្ធផលការអនុវត្តផែនការថវិកាឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូ និងអង្គការមិនមែនរដ្ឋាភិបាល
- រៀបចំសេចក្តីព្រាងយន្តការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការអន្តរជាតិ
- បន្តចុះធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តជំរុញការងារតាមការដ្ឋានសាងសង់ផ្លូវ ដើម្បីបញ្ចប់ការងារឲ្យបានទាន់ពេលវេលា
- បន្តចុះត្រួតពិនិត្យការងារស្ថាបនា និងកែលម្អផ្លូវជនបទ
- អនុវត្តការងារថែទាំ និងជួសជុលផ្លូវនៅតាមបណ្ដាខេត្ត
- បន្តការងារបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌផ្លូវ
- បណ្តុះបណ្តាលនីតិវិធីពិសោធន៍ទៅលើផ្នែកដី បេតុង កៅស៊ូ និងផ្នែកពិសោធន៍ចល័ត
- អនុវត្តការងារពិសោធន៍សំណាកគំរូសម្រាប់ផ្នែកដី បេតុង កៅស៊ូ ដែលទទួលបាន និងបន្តទទួលសំណាកគំរូពីបណ្តាអ្នកទទួលការ និងក្រុមហ៊ុនឯកជននានា សំដៅពង្រឹងការងារពិសោធន៍ឱ្យកាន់តែមានសុក្រឹតភាព និងទាន់ពេលវេលា
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃសំណង់ប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ ទូទាំង ២៥ រាជធានី-ខេត្ត
- ផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្ដីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- បន្តការរៀបចំផែនការ និងកិច្ចសហការនានាជាមួយអង្គការដៃគូនានាលើកម្មវិធីលើកកម្ពស់អនាម័យជនបទ
- បន្តសហការសាកល្បងការផ្ទេរមុខងារអនាម័យទៅរដ្ឋបាលថ្នាក់ស្រុកទាំង ១៥ ក្នុងខេត្តគោលដៅទាំង ០៣ គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- សិក្សាស្រុកគោលដៅថ្មី និងរៀបចំឯកសារគតិយុត្តសម្រាប់ស្រុកចំនួន ១៥ ដែលត្រូវសាកល្បងផ្ទេរមុខងារអនាម័យ
- ត្រៀមរៀបចំពិនិត្យសារឡើងវិញនូវផែនការសកម្មភាពជាតិជំហានទី១ (២០១៤-២០១៨) និងរៀបចំធ្វើផែនការសកម្មភាពជាតិជំហានទី២ ស្តីពី ការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទ (២០១៩-២០២៣)
- អនុវត្តសកម្មភាពពង្រឹងសមត្ថភាព គ.អ.ភ តាមផែនការថវិកាតាមកម្មវិធីឆ្នាំ ២០២១
- សម្របសម្រួលជាមួយមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ឲ្យបន្តខិតខំស្វែងរកកិច្ចសហការ និងការគាំទ្រពីគម្រោងកម្មវិធី និងអង្គការនានា ក្នុងការពង្រឹងសមត្ថភាព គ.អ.ភ
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានចល័ត និងបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់សម្របសម្រួលវគ្គតាមមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានចល័ត

- រិះរកដៃគូក្នុងការផ្តល់វគ្គបណ្តុះបណ្តាលខ្លីៗ ដែលជាប្រធានបទអាទិភាពបានរកឃើញក្នុងការកំណត់តម្រូវការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពមន្ត្រីរាជការ
- បណ្តុះបណ្តាលខ្លីៗ ស្តីពី ប្រធានបទអាទិភាព ដែលបានរកឃើញក្នុងការកំណត់តម្រូវការបណ្តុះបណ្តាលកាលពីឆ្នាំ២០២០
- ពង្រឹងប្រព័ន្ធប្រតិបត្តិការក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋដូចជាការងារឥណទានសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ ការបណ្តុះបណ្តាលបំនិនជីវិត ការរកទីផ្សារសម្រាប់ផលិតផលជនបទជាដើម
- បន្តរៀបចំព្រឹត្តការណ៍តាំងពិព័រណ៍ផលិតផលជនបទ និងសហគមន៍
- សិក្សាភូមិគោលដៅដើម្បីរៀបចំកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច
- បន្តការចុះកំណត់អត្តសញ្ញាណ បទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈរបស់ក្រុមជនជាតិដើមភាគតិច ។

## ៤.សេចក្តីសន្និដ្ឋាន

ឆ្លងតាមការអនុវត្តផែនការសកម្មភាព ឆ្នាំ២០២០ នេះ ក្រសួងអភិវឌ្ឍន៍ជនបទ បានខិតខំយ៉ាងខ្លាំងដើម្បីជំនះគ្រប់ឧបសគ្គដែលបានកើតមានឡើងក្នុងឆ្នាំនេះដើម្បីជួយដល់ប្រជាជនជនបទឲ្យរក្សាបានសុខភាពល្អ ប្រាក់ចំណូល សេដ្ឋកិច្ចគ្រួសារនៅជនបទសមស្រប បង្កើតការងារផ្សេងៗតាមរយៈសាច់ប្រាក់ពលកម្ម បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋាន ផ្តល់ឥណទានក្នុងអត្រា ការប្រាក់ទាប ដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធបានទាន់ពេលវេលាក្នុងអំឡុងពេលជំនន់ទឹកភ្លៀងដែលដាច់ផ្លូវនៅតាមតំបន់ជនបទដោយបានជួសជុល សាងសង់ កែលម្អផ្លូវជនបទឡើងវិញគ្រប់ទីកន្លែង ។

ម្យ៉ាងវិញទៀត ទោះបីជាមានករណីឆ្លងចូលសហគមន៍នៃជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ទាំងពីរលើកនោះក៏ដោយ ក៏ក្រសួងនៅតែបន្តធ្វើការប្រជុំ ពិភាក្សាគ្នាតាមប្រព័ន្ធអនឡាញដើម្បីដោះស្រាយបញ្ហាដែលនៅសេសសល់បានដែរ ដោយពុំទុកឲ្យស្ទះការងារនោះឡើយ ។

ជាចុងក្រោយឆ្នាំ២០២០ នេះបានបិទបញ្ចប់ទៅដោយជោគជ័យក្នុងការអនុវត្តផែនការសកម្មភាពដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមនានា នៅតាមជនបទដើម្បីធានាដល់ជីវភាពរស់នៅរបស់ប្រជាជនជនបទដោយសុខសាន្ត និងនៅតែអាចបន្តសកម្មភាពសេដ្ឋកិច្ចគ្រួសារបានដដែលដោយគ្រាន់តែអនុវត្តតាមវិធាននានារបស់ក្រសួងសុខាភិបាលក្រោមមាគ៌ាដឹកនាំប្រកបដោយភាពវៃឆ្លាតបំផុត របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលធានាបានសុខសន្តិភាព សុវត្ថិភាព ក្នុងជីវភាពរស់នៅ ក្នុងសង្គមកម្ពុជាទាំងមូល ៕

**រដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**